# ការតមអាហាររបស់ វិលហ្វូឌ



ដោយអែលឌើរ
ឈី ហុង ( សាំ ) វុង
នៃពួកចិតសិបនាក់



ថ្ងៃមួយ ខ្ញុំឃើញកូនប្រុសច្បងរបស់ខ្ញុំ វិលហ្វូឌ រៀបចំស្រោមសំបុត្រដង្វាយមួយភាគក្នុងដប់ ។ គាត់មានអាយុប្រហែលជាប្រាំឆ្នាំនាពេលនោះ ។ វិលហ្វូឌ ពុំមានប្រាក់ចំណូលអ្វីទេ ដូច្នេះខ្ញុំឆ្ងល់ថាហេតុអ្វីក៏គាត់បង់ដង្វាយមួយភាគក្នុងដប់ ។ នៅពេលខ្ញុំសួរគាត់ គាត់បានប្រាប់ខ្ញុំថា តាមពិតគាត់បង់ដង្វាយតមអាហារ ។

វិលហ្វូឌ ពុំមានប្រាក់ច្រើនដោយខ្លួនគាត់ទេ ។ ប៉ុន្តែគាត់នៅតែរំភើបចិត្តដើម្បីបង់ដង្វាយតមអាហារ ។

ខ្ញុំមានការស្ញើចសរសើរចំពោះទង្វើនៃសណ្ដានចិត្តដ៏ល្អនេះ ។ ខ្ញុំបានសួរគាត់ថាហេតុអ្វីក៏គាត់សម្រេចចិត្តធ្វើដូច្នោះ ។

វិលហ្វូឌ បានតបថា « ខ្ញុំពុំមានតម្រូវការអ្វីទេ ។ ប៉ុន្តែខ្ញុំដឹងថា អ្នកដទៃមានតម្រូវការ » ។ គាត់បានដឹងថាប្រាក់របស់គាត់ នឹងជួយដល់មនុស្សដទៃ ។ គាត់សប្បាយចិត្តណាស់អំពីរឿងនោះ ។

បទពិសោធន៍ដ៏សាមញ្ញនេះ បានបង្រៀនខ្ញុំនូវមេរៀនដ៏ល្អមួយ ៖ កុមារតូចៗពិតជាត្រូវបានញ៉ាំងចិត្តដោយព្រះវិញ្ញាណ ហើយមានក្ដីស្រឡាញ់ដូចជាព្រះគ្រីស្ទពីធម្មជាតិមែន ។ វិលហ្វូឌ មានអ្វីដែលគាត់ពុំត្រូវការ ហើយបានដឹងថា វានឹងជួយអ្នកដទៃទៀត ។ គាត់ស្ម័គ្រចិត្តធ្វើការលះបង់ ។

ការសន្សំប្រាក់គឺជាការល្អ ។ ប៉ុន្តែកូនប្រុសតូចរបស់ខ្ញុំ បានបង្រៀនខ្ញុំនូវមេរៀនមួយទៀតតាមរយៈគំរូរបស់គាត់ ។ តាមរយៈការស្ដាប់តាមព្រះវិញ្ញាណ នោះយើងអាចប្រទានពរដល់ជីវិតមនុស្សផ្សេងទៀត ពេលយើងចែកចាយនូវអ្វីដែលយើងមាន ។ ■

រូបភាពដោយ ម៉ាត ចាមែន